# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ..០១..សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការអន្តរក្រសួង
## ដើម្បីរៀបចំសន្និសីទថ្នាក់តំបន់ ស្តីពីការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ
## ថ្ងៃទី ១២-១៣ ខែ មីនា ឆ្នាំ២០១៨

## រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ២០១៦ ស្តីពីការបញ្ចប់មុខងារ និងតែងតាំងសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យ ប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាស ឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ

-បានឃើញសេចក្តីសម្រេចលេខ ១៥០សសរ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ២០១៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីរៀបចំសន្និសីទថ្នាក់តំបន់ ស្តីពីការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ នាថ្ងៃទី ១២-១៣ ខែ មីនា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ ដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **មៀច សុផាន់ណា** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិតផលក្លែងក្លាយ (គ.ប.ផ.ក) | **ប្រធាន** |
| ២-ឯកឧត្តម | **ឈឹម យីសាន** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |



www.pheakdeylaw.com

| | | | |
|---|---|---|---|
| ៣-ឯកឧត្តម | **ស៊ា ហួច** | អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល | អនុប្រធាន |
| ៤-ឯកឧត្តម | **ប៉ុក ម៉ាន់នី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាអនុប្រធានគណៈកម្មាធិការ គ.ប.ផ.ក | សមាជិក |
| ៥-ឯកឧត្តម | **គឹម ជាតិ** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការ គ.ប.ផ.ក | សមាជិក |
| ៦-ឯកឧត្តម | **សុខ សារេត** | ទីប្រឹក្សាក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការ គ.ប.ផ.ក | សមាជិក |
| ៧-ឯកឧត្តម | **ថាច់ កេត** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន និងជាសមាជិក គ.ប.ផ.ក | សមាជិក |
| ៨-ឯកឧត្តម | **ហ៊ាន វណ្ណហាន** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងជាសមាជិក គ.ប.ផ.ក | សមាជិក |
| ៩-ឯកឧត្តម | **ឡុន សុមេធ** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍និងជាសមាជិក គ.ប.ផ.ក | សមាជិក |
| ១០-លោកជំទាវ | **ឃុន រចនា** | អនុរដ្ឋលេខាធិការក្រសួងអប់រំ យុវជននិងកីឡា និងជាសមាជិក គ.ប.ផ.ក | សមាជិក |
| ១១-លោកជំទាវ | **ឱ វណ្ណឌីន** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល នៃក្រសួងសុខាភិបាល | សមាជិក |
| ១២-ឯកឧត្តម | **សរ សិទ្ធិ** | ទីប្រឹក្សាក្រសួងមហាផ្ទៃ និងជាសមាជិកអចិន្ត្រៃយ៍ គ.ប.ផ.ក | សមាជិក |
| ១៣-ឯកឧត្តម នាយឧត្តមសេនីយ៍ | **ទូច ណារ៉ុថ** | អគ្គស្នងការរង និងជាប្រធាននាយកដ្ឋានអង្គរក្ស | សមាជិក |
| ១៤-ឯកឧត្តម នាយឧត្តមសេនីយ៍ | **ឃុន សំបូរ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងជាសមាជិក គ.ប.ផ.ក | សមាជិក |
| ១៥-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ស៊ិន សុផាន្នី** | មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជាសមាជិក គ.ប.ផ.ក | សមាជិក |
| ១៦-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឌី ទិដ្ឋា** | ប្រធាននាយកដ្ឋាន កណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| ១៧-ឯកឧត្តម | **ញឹម ខេមរា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១៨-ឯកឧត្តម | **គឹម មាសសុខសីហា** | អគ្គនាយករងកាំកុងត្រូល នៃក្រសួងពាណិជ្ជកម្ម និងជាសមាជិកគ.ប.ផ.ក | សមាជិក |



www.pheakdeylaw.com

| | | | |
|---|---|---|---|
| ១៩-លោកទន្តបណ្ឌិត | អឿន ឃ្វូរ៉ាវត្តន៍ | អគ្គនាយករងបច្ចេកទេសសុខាភិបាល ក្រសួងសុខាភិបាល និងជាសមាជិក គ.ប.ផ.ក | សមាជិក |
| ២០-ឯកឧត្តម | សៀង ប៊ុនធុង | អគ្គលេខាធិការរង នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ២១-ឯកឧត្តម ឧត្តមសេនីយ៍ឯក | ចាន់ ថ័ន់ធឿន | ប្រធាននាយកដ្ឋាន នគរបាលប្រឆាំងបទល្មើសសេដ្ឋកិច្ច និងជាសមាជិក គ.ប.ផ.ក | សមាជិក |
| ២២-លោកឧត្តមសេនីយ៍ទោ | លីម សុផាណារិទ្ធិ | សមាជិក គ.ប.ផ.ក និងជាប្រធានលេខាធិការដ្ឋាន នៃគ.ប.ផ.ក | សមាជិក |
| ២៣-លោក | អ៊ិន សំបូរ | អនុប្រធានវិទ្យាស្ថានស្តង់ដារកម្ពុជា នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ២៤-លោកឧត្តមសេនីយ៍ទោ | និត្យ ថិសិដ្ឋ | ទីប្រឹក្សា គ.ប.ផ.ក | សមាជិក |
| ២៥-លោកឧត្តមសេនីយ៍ត្រី | ព្រុំ សន្ធរ | ស្នងការរងនគរបាលរាជធានីភ្នំពេញ | សមាជិក |

គណៈកម្មការនេះ មានតួនាទី និងភារកិច្ចដឹកនាំ និងសម្របសម្រួលការរៀបចំសន្និសីទថ្នាក់តំបន់ ស្តីពីការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ នាថ្ងៃទី ១២-១៣ ខែ មីនា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ ឲ្យទទួលបានជោគជ័យ ។

**ប្រការ ២.-**

ត្រូវបានបង្កើតលេខាធិការដ្ឋាន និងអនុគណៈកម្មការ នៃគណៈកម្មការអន្តរក្រសួងដើម្បីរៀបចំ សន្និសីទថ្នាក់តំបន់ ស្តីពីការប្រយុទ្ធប្រឆាំងឱសថក្លែងក្លាយ ដែលមានសមាសភាព និងភារកិច្ចដូច ខាងក្រោម ៖

**ក-លេខាធិការដ្ឋាន**

| | | | |
|---|---|---|---|
| ១-លោកឧត្តមសេនីយ៍ទោ | លីម សុផាណារិទ្ធិ | សមាជិក គ.ប.ផ.ក និងជាប្រធានលេខាធិការដ្ឋាន នៃ គ.ប.ផ.ក | ប្រធាន |
| ២-លោកឧត្តមសេនីយ៍ទោ | ផាត សុផានិត | ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣-លោក | ភិន វិជ្ជាចឡ្យនា | ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ និងគណនេយ្យ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤-លោកឧត្តមសេនីយ៍ត្រី | ម្ទូច ឫទ្ធី | អនុប្រធានលេខាធិការដ្ឋាន នៃ គ.ប.ផ.ក | សមាជិក |
| ៥-លោកវរសេនីយ៍ឯក | កែវ ហុកលី | អនុប្រធានលេខាធិការដ្ឋាន នៃ គ.ប.ផ.ក | សមាជិក |
| ៦-លោកវរសេនីយ៍ឯក | វណ្ណា ផេង | អនុប្រធានលេខាធិការដ្ឋាន នៃ គ.ប.ផ.ក | សមាជិក |
| ៧-លោក | លាង អៀម | ប្រធានការិយាល័យសង្គមកិច្ចទី២ នាយកដ្ឋានហិរញ្ញកិច្ច នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៨-លោក | គន្ធ សុធីរ | ជំនួយការប្រធាន គ.ប.ផ.ក | សមាជិក |



www.pheakdeylaw.com

លេខាធិការដ្ឋាន មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-ជាជំនួយដល់គណៈកម្មការក្នុងការដឹកនាំ ចាត់ចែង ត្រួតពិនិត្យ សម្របសម្រួលជាមួយស្ថាប័ន និងអង្គភាពពាក់ព័ន្ធ

-រៀបចំកិច្ចប្រជុំបច្ចេកទេសនានាសម្រាប់គណៈកម្មការអន្តរក្រសួង

-រៀបចំអញ្ជើញភ្ញៀវជាតិ និងអន្តរជាតិចូលរួមសន្និសីទ

-រៀបចំស្លាកពាក់សម្រាប់ភ្ញៀវជាតិ និងអន្តរជាតិចូលរួមសន្និសីទ

-រៀបចំប័ណ្ណចតរថយន្តសម្រាប់ភ្ញៀវជាតិ និងអន្តរជាតិចូលរួមសន្និសីទ

-រៀបចំ និងសម្រួលដល់ការស្នាក់នៅ និងហូបចុក របស់គណៈប្រតិភូជាតិ និងអន្តរជាតិ

-លើកគម្រោងផែនការ ចំណាយសម្រាប់ដំណើរការសន្និសីទ

-រៀបចំមធ្យោបាយធ្វើដំណើរ ជូនភ្ញៀវជាតិ និងអន្តរជាតិ

-រៀបចំវត្ថុអនុស្សាវរីយ៍ សម្រាប់ជូនដល់គណៈប្រតិភូ នៃបណ្តាប្រទេសដែលបានមកចូលរួម

-សហការជាមួយអនុគណៈកម្មការហិរញ្ញវត្ថុ ដើម្បីចាត់ចែងការងារហិរញ្ញវត្ថុ

-ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានគណៈកម្មការអន្តរក្រសួងប្រគល់ជូន ។

**ខ-អនុគណៈកម្មការរៀបចំឯកសារ និងខ្លឹមសារសន្និសីទ**

| | | | |
|---|---|---|---|
| ១-លោកជំទាវ | **ឱ វណ្ណាឌីន** | អគ្គនាយក នៃអគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល នៃក្រសួងសុខាភិបាល | ប្រធាន |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សរ សិទ្ធិ** | ទីប្រឹក្សាក្រសួងមហាផ្ទៃ និងជាសមាជិកអចិន្ត្រៃយ៍ នៃ គ.ប.ផ.ក | អនុប្រធាន |
| ៣-លោកឱសថបណ្ឌិត | **ហេង ប៊ុនគៀត** | ប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង នៃក្រសួងសុខាភិបាល | អនុប្រធាន |
| ៤-លោកឱសថការី | **ហួត សេងថុង** | អនុប្រធាននាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាង នៃក្រសួងសុខាភិបាល និងជាសមាជិក គ.ប.ផ.ក | សមាជិក |
| ៥-លោកឧត្តមសេនីយ៍ត្រី | **សុខ សុមនោ** | ជំនួយការ ប្រធាន គ.ប.ផ.ក និងជា សមាជិក គ.ប.ផ.ក | សមាជិក |
| ៦-លោកឧត្តមសេនីយ៍ត្រី | **យិត គីរះ** | អនុប្រធានលេខាធិការដ្ឋាន នៃ គ.ប.ផ.ក | សមាជិក |
| ៧-លោកបណ្ឌិត | **ឯម ឧត្តរីន័** | ជំនួយការប្រធាន គ.ប.ផ.ក | សមាជិក |
| ៨-លោក | **ហេង ហុក** | ប្រធានការិយាល័យ នៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-រៀបចំខ្លឹមសារឯកសារពាក់ព័ន្ធនានាសម្រាប់ដំណើរការសន្និសីទ

-រៀបចំបោះពុម្ពឯកសារសំខាន់ៗពាក់ព័ន្ធនឹងសន្និសីទ



www.pheakdeylaw.com

-រៀបចំសុន្ទរកថា និងជំនួយស្មារតីសម្រាប់ប្រធានគណៈអធិបតីក្នុងពិធីបើក និងបិទ
-រៀបចំខ្លឹមសារបូកសរុបលទ្ធផល នៃសន្និសីទ
-រៀបចំសេចក្តីប្រកាសព័ត៌មាន ឬសេចក្តីសម្រេចចិត្តអំពីលទ្ធផល នៃសន្និសីទ
-រៀបចំឯកសារបទបង្ហាញ និងជំនួយស្មារតី សម្រាប់ភាគីកម្ពុជាឡើងធ្វើបទបង្ហាញ
-ធ្វើរបាយការណ៍ពីលទ្ធផល នៃសន្និសីទជូនរាជរដ្ឋាភិបាល
-ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានគណៈកម្មការអន្តរក្រសួងប្រគល់ជូន ។

**គ-អនុគណៈកម្មការព័ត៌មាន និងផ្សព្វផ្សាយ**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ថាច់ កេត** | អនុរដ្ឋលេខាធិការក្រសួងព័ត៌មាន និងជាសមាជិក គ.ប.ជ.ក | ប្រធាន |
| ២-ឯកឧត្តម | **ប៉ុក ម៉ាន់នី** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ និងជាអនុប្រធានគណៈកម្មាធិការ គ.ប.ជ.ក | អនុប្រធាន |
| ៣-ឯកឧត្តម | **សុខ សារេត** | ទីប្រឹក្សាក្រសួងមហាផ្ទៃ និងជា អនុប្រធានគណៈកម្មាធិការ គ.ប.ជ.ក | អនុប្រធាន |
| ៤-ឯកឧត្តម | **ឃឹម ឧត្តរី** | អគ្គនាយកទូរទស្សន៍ជាតិកម្ពុជា | អនុប្រធាន |
| ៥-ឯកឧត្តម | **ពេញ វិបុល** | ព្រះរាជអាជ្ញា និងជាអគ្គនាយករង នៃអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌ ក្រសួងយុត្តិធម៌ និងជា សមាជិក គ.ប.ជ.ក | សមាជិក |
| ៦-ឯកឧត្តម | **អួន ពិសាល** | អគ្គាធិការរង នៃអគ្គាធិការដ្ឋាន កិច្ចការតុលាការ ក្រសួងយុត្តិធម៌ | សមាជិក |
| ៧-លោកឧត្តមសេនីយ៍ត្រី | **ម៉ា សំណាង** | អនុប្រធានលេខាធិការដ្ឋាន នៃ គ.ប.ជ.ក | សមាជិក |
| ៨-លោកវរសេនីយ៍ឯក | **ម៉ក់ ធារ៉ា** | អនុប្រធានលេខាធិការដ្ឋាន នៃ គ.ប.ជ.ក | សមាជិក |
| ៩-លោក | **ព្រំ អធិតា** | អនុប្រធាននាយកដ្ឋាន នៃអគ្គនាយកដ្ឋានអាស៊ាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ១០-លោកវរសេនីយ៍ឯក | **គួ សុផល** | នាយការិយាល័យ ផ្សព្វផ្សាយ អប់រំ បង្ការ ទប់ស្កាត់ និងការពារ នៃ លេខាធិការដ្ឋានគ.ប.ជ.ក | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-សហការជាមួយអនុគណៈកម្មការរៀបចំឯកសារ និងខ្លឹមសារ ដើម្បីរៀបចំអត្ថបទព័ត៌មាន ផ្សព្វផ្សាយអំពីសន្និសីទ
-ផ្សព្វផ្សាយនូវព័ត៌មាននៃសន្និសីទ មុន និងអំឡុងពេលនៃការរៀបចំសន្និសីទ តាមរយៈគេហទំព័របណ្តាញសង្គម ទូរទស្សន៍ វិទ្យុ បដា ពាក្យស្លោក ផ្ទាំងប៉ាណូតូច-ធំ



www.pheakdeylaw.com

-ធ្វើការឃោសនាផ្សព្វផ្សាយពីសន្និសីទនេះតាមគ្រប់រូបភាព និងមធ្យោបាយ ដោយសហការជាមួយប្រព័ន្ធផ្សព្វផ្សាយព័ត៌មានក្នុងស្រុក និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

-ផ្សព្វផ្សាយឲ្យបានទូលំទូលាយតាមគ្រប់មធ្យោបាយ គ្រប់រូបភាពទាំងក្នុង និងក្រៅប្រទេស

-រៀបចំចងក្រងនូវឯកសារវីដេអូសកម្មភាពទាំងស្រុង នៃសន្និសីទ

-ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានគណៈកម្មការអន្តរក្រសួងប្រគល់ជូន ។

**ឃ-អនុគណៈកម្មការរៀបចំបដិសណ្ឋារកិច្ច ពិធីការ និងដឹកជញ្ជូន**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម | **ឈីវ យីសាង** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២-ឯកឧត្តម | **គឹម ជាតិ** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានគណៈកម្មាធិការ គ.ប.ផ.ក | អនុប្រធាន |
| ៣-ឯកឧត្តម នាយឧត្តមសេនីយ៍ | **ឃុន សំបូរ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ និងជាសមាជិកគ.ប.ផ.ក | អនុប្រធាន |
| ៤-ឯកឧត្តម | **ម៉ែន ប៊ុនរិទ្ធ** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន និងជាប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៥-ឯកឧត្តម | **សៀង ប៊ុនឌុង** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៦-ឯកឧត្តម | **ឈុន ថុង** | ប្រធាននាយកដ្ឋានផ្គត់ផ្គង់ នៃទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៧-លោក | **ខៀវ រិទ្ធីយ៉ា** | ប្រធាននាយកដ្ឋានពិធីការ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៨-លោកស្រីឧត្តមសេនីយ៍ទោ | **ទី សាឌី** | ជំនួយការប្រធាន គ.ប.ផ.ក | សមាជិក |
| ៩-លោកឧត្តមសេនីយ៍ទោ | **ទិត ទិសិដ្ឋ** | អនុប្រធាននាយកដ្ឋានលិខិតឆ្លងដែន នៃអគ្គនាយកដ្ឋាន អត្តសញ្ញាណកម្ម និងជាទីប្រឹក្សា គ.ប.ផ.ក | សមាជិក |
| ១០-លោកឧត្តមសេនីយ៍ត្រី | **ចី ណាស៊ី** | អនុប្រធានលេខាធិការដ្ឋាន នៃ គ.ប.ផ.ក | សមាជិក |
| ១១-លោកឧត្តមសេនីយ៍ត្រី | **ខាន់ លីណា** | អនុប្រធានលេខាធិការដ្ឋាន នៃ គ.ប.ផ.ក | សមាជិក |
| ១២-លោកវរសេនីយ៍ឯក | **មាន ភក្តរា** | អនុប្រធានលេខាធិការដ្ឋាន នៃ គ.ប.ផ.ក | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-រៀបចំទីតាំង តុបតែងវេទិកា គណៈអធិបតី កន្លែងអង្គុយ និងពិធីការសម្រាប់ឥស្សរជនជាតិ និងអន្តរជាតិ

-រៀបចំទទួលស្វាគមន៍គណៈប្រតិភូជាតិ និងអន្តរជាតិ

-រៀបចំ និងសម្របសម្រួលការធ្វើដំណើរ ជូនភ្ញៀវជាតិ និងអន្តរជាតិ



www.pheakdeylaw.com

-រៀបចំដឹកជញ្ជូន និងដំណើរទស្សនកិច្ចជូនភ្ញៀវជាតិ និងអន្តរជាតិ
-សហការជាមួយ លេខាធិការដ្ឋាន ដើម្បីសម្របសម្រួលការងារផ្សេងៗ
-ទទួលភារកិច្ចផ្សេងៗទៀត ដែលប្រធានគណៈកម្មការអន្តរក្រសួងប្រគល់ជូន ។

**ខ-អនុគណៈកម្មការការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ សុខភាព និង សង្គ្រោះបន្ទាន់**

| | | | |
|---|---|---|---|
| ១-ឯកឧត្តម នាយឧត្តមសេនីយ៍ | **ទូច ណារ៉ុថ** | អគ្គស្នងការរង និងជាប្រធាននាយកដ្ឋានអង្គរក្ស | ប្រធាន |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ស៊ិន សុផាន្នី** | មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងជាសមាជិក គ.ប.ផ.ក | អនុប្រធាន |
| ៣-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **ឌី ទិដ្ឋា** | ប្រធាននាយកដ្ឋាន កណ្តាលសន្តិសុខ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | អនុប្រធាន |
| ៤-ឯកឧត្តម ឧត្តមសេនីយ៍ឯក | **សុខ ខេមរិន្ទ** | ប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌ | អនុប្រធាន |
| ៥-លោកឧត្តមសេនីយ៍ទោ | **ឌិត្យ គឹមអ៊ិន** | អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទណ្ឌនិងជាសមាជិក គ.ប.ផ.ក | អនុប្រធាន |
| ៦-លោកឧត្តមសេនីយ៍ទោ | **អ៊ូច ទូច** | អនុប្រធានលេខាធិការដ្ឋាននៃ គ.ប.ផ.ក | អនុប្រធាន |
| ៧-លោកឧត្តមសេនីយ៍ត្រី | **ព្រុំ សន្ធរ** | ស្នងការរងនគរបាលរាជធានីភ្នំពេញ | អនុប្រធាន |
| ៨-លោកឧត្តមសេនីយ៍ត្រី | **ជ័យ រិទ្ធី** | អនុប្រធានលេខាធិការដ្ឋាននៃ គ.ប.ផ.ក | សមាជិក |
| ៩-លោកឧត្តមសេនីយ៍ត្រី | **ជុត សាម៉ុន** | អនុប្រធានលេខាធិការដ្ឋាននៃ គ.ប.ផ.ក | សមាជិក |
| ១០-លោកឧត្តមសេនីយ៍ត្រី | **ទូច យុទ្ធា** | អនុប្រធានលេខាធិការដ្ឋាននៃ គ.ប.ផ.ក | សមាជិក |
| ១១-លោកវរសេនីយ៍ទោ | **អ៊ិន លុច** | នាយការិយាល័យនៃលេខាដ្ឋាន គ.ប.ផ.ក | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-រៀបចំការពារសន្តិសុខ របៀបរបប សណ្តាប់ធ្នាប់ និងចរាចរ និងធានាសុវត្ថិភាពឲ្យបាន គ្រប់គ្រាន់នៅមុន និងក្រោយពេលប្រារព្ធពិធី និងតាមផ្លូវឆ្លងកាត់
-ទំនាក់ទំនង និងសហការជិតស្និទជាមួយអាជ្ញាធរមានសមត្ថកិច្ចនៅអាកាសយានដ្ឋានអន្តរជាតិ និងតាមច្រកទ្វារព្រំដែនអន្តរជាតិ ដើម្បីបង្កលក្ខណៈងាយស្រួលដល់គណៈប្រតិភូ និងភ្ញៀវ អន្តរជាតិដែលអញ្ជើញចូលរួម
-ត្រៀមលក្ខណៈ និងមធ្យោបាយគ្រប់គ្រាន់សម្រាប់សង្គ្រោះបន្ទាន់ ក្នុងករណីមានបាតុភាពជាយថាហេតុ
-ត្រៀម គ្រូពេទ្យ ថ្នាំពេទ្យ សម្រាប់ជួយបម្រើសុខភាពភ្ញៀវ
-ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានគណៈកម្មការអន្តរក្រសួងប្រគល់ជូន ។



www.pheakdeylaw.com

**ច-អនុគណៈកម្មការហិរញ្ញវត្ថុ**

| | | |
|---|---|---|
| ១-ឯកឧត្តម **ញឹម ខេមរា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២-ឯកឧត្តម ឧត្តមសេនីយ៍ឯក **ចាន់ សុវណ្ណ** | ប្រធាននាយកដ្ឋាន ផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣-លោក **ហេង ស៊ីធឿន** | ប្រធាននាយកដ្ឋានហិរញ្ញកិច្ច នៃអគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៤-លោកឧត្តមសេនីយ៍ទោ **ជា សុគន្ធា** | អនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ | សមាជិក |
| ៥-លោកឧត្តមសេនីយ៍ត្រី **អ៊ិន សុភ័ក្ត្រ** | អនុប្រធានលេខាធិការដ្ឋាន នៃ គ.ប.ជ.ក | សមាជិក |
| ៦-លោក **ម៉ែន វណ្ណា** | អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ គណនេយ្យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧-លោកវរសេនីយ៍ឯក **ចាន់ ទាសនា** | នាយការិយាល័យរដ្ឋបាលសរុប នៃ លេខាធិការដ្ឋានគ.ប.ជ.ក | សមាជិក |
| ៨-លោក **ម៉ុច វណ្ណា** | ប្រធានក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួងសុខាភិបាល នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |

អនុគណៈកម្មការនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

-គ្រប់គ្រង និងរៀបចំការងារហិរញ្ញវត្ថុ ចំណូល ចំណាយ គ្រប់សកម្មភាព នៃដំណើការរៀបចំសន្និសីទ

-បូកសរុបចំណូល-ចំណាយ

-សហការជាមួយលេខាធិការដ្ឋាន ដើម្បីចាត់ចែងការងារហិរញ្ញវត្ថុ

-ទទួលភារកិច្ចផ្សេងៗទៀតដែលប្រធានគណៈកម្មការអន្តរក្រសួងប្រគល់ជូន ។

**ប្រការ ៣.-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការ ឬក្រុមការងារបន្ថែម តាមការ ចាំបាច់ ។ អនុគណៈកម្មការនីមួយៗ និងលេខាធិកាដ្ឋាន អាចស្នើសុំជ្រើសរើសសមាជិកបន្ថែមតាមការ ចាំបាច់ ដោយមានការយល់ព្រមពីប្រធានគណៈកម្មការអន្តរក្រសួង ។

**ប្រការ ៤.-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ថវិការបស់រាជរដ្ឋាភិបាល និងប្រភពថវិកា ស្របច្បាប់ផ្សេងៗទៀត ដើម្បីដំណើរការការងាររបស់ខ្លួន ។

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិស្វែងរកដៃគូអភិវឌ្ឍន៍ ឬផ្នែកឯកជន ដើម្បីជួយទ្រទ្រង់ និងឧបត្ថម្ភដល់ដំណើរការសន្និសីទ ។



www.pheakdeylaw.com

**ប្រការ ៥.-**

គណៈកម្មការអន្តរក្រសួងនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ដើម្បីដំណើរការការងាររបស់ខ្លួនតាមការចាំបាច់ ។

អនុប្រធាន សមាជិកគណៈកម្មការ ប្រធាន អនុប្រធាន សមាជិកអនុគណៈកម្មការ និងលេខាធិការដ្ឋាន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការអន្តរក្រសួង ។

**ប្រការ ៦.-**

គណៈកម្មការអន្តរក្រសួងនេះ នឹងត្រូវរំសាយក្រោយពេលចប់ភារកិច្ច ។

**ប្រការ ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល ប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងផលិត ផលក្លែងក្លាយ ដែលបង្កគ្រោះថ្នាក់មានហានិភ័យខ្ពស់ដល់សុខភាព និងសុវត្ថិភាពសង្គម និងប្រធាន គ្រប់ស្ថាប័ន អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ និងសាមីខ្លួនដូចមានចែងក្នុង ប្រការ១ និងប្រការ២ ត្រូវទទួលអនុវត្តន៍តាមសេចក្ដីសម្រេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

ថ្ងៃពុធ ៨ រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែមករា ឆ្នាំ២០១៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ក្រសួងស្ថាប័នពាក់ព័ន្ធ
- -ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- -ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- -ដូចប្រការ ៨
- -រាជកិច្ច
- -ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com